# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0092**

## សម្ភាសន៍ជាមួយឈ្មោះ ស៊ិន សន ភេទប្រុស អាយុ៨៨ឆ្នាំ
## មុខងារជំនាន់ខ្មែរក្រហម "កម្មករពេងចក្រ"ដ៧"
## រស់ភូមិជន្សៀសដៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០
## សម្ភាសន៍ដោយៈ សុខ វណ្ណៈ
## ០១ៈ១២ៈ៥៦
## ២៣ទំព័រ

វណ្ណៈ ចឹងជាដំបូងខ្ញុំចង់ណែនាំខ្លួនខ្ញុំឲ្យពូស្គាល់ថា ខ្ញុំឈ្មោះសុខ វណ្ណៈ ។

សនៈ បាទ ។

វណ្ណៈ ខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា
ហើយខ្ញុំបានមកដល់ភូមិឃុំរបស់ពូគឺចង់ដឹងរឿង រ៉ាវនៅស្រុកស្វាយចេកចឹងណាស់ ។

សនៈ បាទ ។

វណ្ណៈ ខេត្តបន្ទាយមានជ័យនេះ និងចង់រឿងរ៉ាវដែលជាប្រវត្តិផ្ទាល់ខ្លួនរបស់ពូ?

សនៈ បាទ ។

វណ្ណៈ ថាធ្លាប់ឆ្លងកាត់អ្វីខ្លះ ធ្លាប់បែកបាក់គ្រួសារយ៉ាងម៉េចៗ បានជាមកដល់នេះមានប្រពន្ធកូនចៅយ៉ាងម៉េចខ្លះ?

សនៈ បាទ ។

វណ្ណៈ កសាងជីវភាពនៅទីហ្នឹង មិនបានត្រឡប់ទៅស្រុកកំណើតវិញ ដោយសារតែមូលហេតុអីចឹង ណាពូណាស់?

សនៈ បាទ ។

វណ្ណៈ ហើយបទសម្ភាសន៍ខ្ញុំជាមួយពូទុកជាឯកសារទុកឲ្យក្មេងជំនាន់ក្រោយ តើពូអនុញ្ញាតទេ?

សនៈ ខ្ញុំមិនថាអីទេ បើនិយាយប្រវត្តិទៅវាវែងឆ្ងាយណាស់ ។

វណ្ណៈ បាទ ។

សនៈ វាច្រើនម៉ោងណាស់ ។

វណ្ណៈ ចឹងបទសម្ភាសន៍ខ្ញុំជាមួយពូ ពូអនុញ្ញាតឲ្យប្រើការបាន?

សនៈ	បាទ! ចឹងចង់ក្មេងជំនាន់ក្រោយបានដឹងត្រូវហើយ ការលំបាកការបាក់បែកឪពុកម្ដាយដោយសារអ្វី ។

វណ្ណៈ	បាទ ។

សនៈ	បើខ្ញុំនិយាយឲ្យចំទៅវាមិនមានអីទេ មានតែសង្គ្រាមហ្នឹងឯងឲ្យយើងនេះបាក់បែងឪពុកម្ដាយរហូតចេញពីភូមិស្រុកគេមកហ្នឹង ។

វណ្ណៈ	បាទ ។

សនៈ	ដូចនេះចេះតែស្វែងរកដើម្បីជីវិតទៅ រស់នៅមានប្រពន្ធកូនអីចឹងទៅ ចង់ត្រឡប់ទៅស្រុកវិញទៅតែដីនៅទីនោះវាចង្អៀតដែរ ។

វណ្ណៈ	បាទ ។

សនៈ	ដូចនេះប្រកបការងារទៅគិតថាប្រកបការងារនេះទៅចុះ ។

វណ្ណៈ	បាទ ។

សនៈ	ដើម្បីមានសុភមង្គលសល់កូន ។

វណ្ណៈ	ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ?

សនៈ	ខ្ញុំឈ្មោះ ស៊ិន សន ។

វណ្ណៈ	ពូអាយុប៉ុន្មានហើយ?

សនៈ	ខ្ញុំអាយុ៤៨ឆ្នាំ ។

វណ្ណៈ	ចឹងប្រពន្ធពូឈ្មោះអីដែរ?

សនៈ	ឈ្មោះប៉ាន់ ម៉ិ ។

វណ្ណៈ	គាត់អាយុប៉ុន្មានដែរ?

សនៈ	អាយុ៤០ឆ្នាំ ។

វណ្ណៈ	មានកូនប៉ុន្មានរាល់ថ្ងៃ?

សនៈ	មានកូន៤នាក់ ។

វណ្ណៈ	ស្រីប៉ុន្មាន?

សនៈ	ស្រីមួយប្រុស៣ ។

វណ្ណៈ	ចឹងឪពុកពូឈ្មោះអី?

សនៈ	ឈ្មោះ ស៊ិន ស៊ុំ ។

វណ្ណៈ	ម្ដាយឈ្មោះ?

សនៈ ឈ្មោះ សួស ចៀន ។

វណ្ណៈ ចឹងរាល់ថ្ងៃគាត់ទាំងពីរនាក់ហ្នឹងនៅរស់ទេ?

សនៈ គាត់ស្លាប់អស់ហើយ ។

វណ្ណៈ គាត់ស្លាប់ជំនាន់ណា?

សនៈ ស្លាប់ជំនាន់នេះឯង ។

វណ្ណៈ ចឹងបងប្អូនបង្កើតពូប៉ុន្មាននាក់?

សនៈ បងប្អូនមាន៩នាក់ ។

វណ្ណៈ នៅរស់ទាំងអស់?

សនៈ ស្លាប់ទាំងអស់ ។

វណ្ណៈ ស្លាប់សម័យណា?

សនៈ ស្លាប់សម័យហ្នឹង តែមានមួយស្លាប់សម័យសង្គ្រាម តែបាត់ឈ្មោះសម័យសង្គ្រាមទម្លាក់សម្តេចហ្នឹងណាស់ ។

វណ្ណៈ សម័យរដ្ឋប្រហា?

សនៈ បាទ!សម័យរដ្ឋប្រហាទម្លាក់សម្តេច ។

វណ្ណៈ កាលហ្នឹងចូលយោធាសម័យរំដោះដែរ?

សនៈ កាលហ្នឹងវាច្របូកច្របល់ខ្ញុំក្តាប់វាមិនបានផង កាលហ្នឹងខ្ញុំនៅក្មេងដែរ កាលហ្នឹងខ្ញុំនៅរៀន បងៗគេធំទៅគេចូលសម័យហ្នឹងទៅ កាលហ្នឹងគេផ្សព្វផ្សាយចឹងទៅគាត់នៅមិនបានក៏ចូលទៅកាន់ដាវរំពែងហ្នឹងគេទៅសម័យនោះក៏បាត់គាត់ជ្រាបទៅ ។

វណ្ណៈ ចឹងខ្ញុំចង់ដឹងថាស្រុកកំណើត?

សនៈ មិនដឹងនៅភូមិអីទេ ម៉ែវាបានចាំ ។

វណ្ណៈ ចឹងឃុំ?

សនៈ ឃុំព្រៃពួច ខេត្តកណ្តាល ។

វណ្ណៈ ស្រុក?

សនៈ អាអូនទៅយកអត្តសញ្ញាណប័ណ្ណឲ្យពុក ។

វណ្ណៈ ចឹងឥឡូវនៅភូមិអី?

សនៈ នៅភូមិជន្លាស់ដៃ ឃុំគោកកឋិន ។

វណ្ណៈ ស្រុក?

សនៈ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

វណ្ណៈ ចឹងកាលពីនៅតូចពូរៀនបានដល់ថ្នាក់ណា?

សនៈ បើនិយាយពីសព្វថ្ងៃហ្នឹង កាលហ្នឹងគេហៅថ្នាក់ទី១១ ។

វណ្ណៈ ចឹងថ្នាក់ទី១១ចាស់?

សនៈ បាទ! កាលហ្នឹងរៀននៅសាលាវត្ត ។

វណ្ណៈ កាលរៀននៅវត្តណា?

សនៈ វត្តព្រះនាង ។

វណ្ណៈ ចឹងកាលហ្នឹងរៀននៅក្នុងវត្តទេ?

សនៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងពូរៀនបានថ្នាក់ទី១១ហើយឈប់ដោយសារអី?

សនៈ ដោយសារសង្គ្រាមហ្នឹងហើយ ។

វណ្ណៈ ឈប់រៀនមកធ្វើអីទៀត?

សនៈ ឈប់រៀនមកធ្វើស្រែជាមួយឪពុកម្តាយ កាលហ្នឹងរៀនមិនបានយន្តហោះទម្លាក់ឈប់ឲ្យកូនទៅរៀន ។

វណ្ណៈ ចឹងកាលហ្នឹងមានយន្តហោះទម្លាក់?

សនៈ បាទ ។

វណ្ណៈ មានដឹងថាត្រូវប្រជាជនស្លាប់អីទេ?

សនៈ កាលនៅភូមិខ្ញុំមានឆេះ មានផុងជ័រវាទម្លាក់មកត្រូវត្រង់សេឆេះអស់ពីរបីគ្រួសារភូមិព្រៃទទឹង ។

វណ្ណៈ ឆេះផ្ទះ?

សនៈ ឆេះផ្ទះផងឆេះមនុស្សនៅក្នុងរណ្តៅ ស្លាប់អស់ប៉ុន្មានគ្រួសារ ។

វណ្ណៈ ចឹងកាលពូចូលបដិវត្តន៍ដោយសារការទម្លាក់គ្រាប់បែកឬមួយដោយសារគេចាប់ពូ?

សនៈ កាលដែលចូលនោះខ្ញុំនៅតូចមិនដឹងជាឪពុកខ្ញុំយ៉ាងណា ខ្ញុំមិនដឹងប្រវត្តិឪពុកខ្ញុំ តែខ្ញុំដឹងច្បាស់មែនទែននេះ ដឹងកាលសម័យប៉ុល ពតរំដោះនោះខ្ញុំដឹងកាលនោះ ។

វណ្ណៈ ចឹងពូចូលបដិវត្តន៍ឆ្នាំណាពូមានចាំទេ?

សនៈ ខ្ញុំចូលក្រោយ ។

វណ្ណៈ ចឹងចូលកាលឆ្នាំ៧៥?

សនៈ បាទ!ចូល៧៥ហ្នឹង ចូលថាក្រុមកុមារគេនោះណាស់ តែសម័យនោះខ្ញុំមិនបានដឹងទេ មានតែបងៗខ្ញុំ ដល់៧៥នេះបានខ្ញុំដឹងច្បាស់ ។

វណ្ណៈ ដឹងច្បាស់យ៉ាងម៉េចទៅ?

សនៈ ខ្ញុំកាលហ្នឹងនៅតាមកងចល័តអីហ្នឹង កាលហ្នឹងខ្ញុំទៅនៅកណ្ដាលភ្នំពេញបណ្ដោយ ។

វណ្ណៈ ចឹងកាល៧៥ហ្នឹងមកនៅភ្នំពេញ?

សនៈ បាទ!នៅរោងចក្រក្រឡឹងដែក"ដ៧"ចក្រអង្រែក្រោមយើងនេះណាស់ ។

វណ្ណៈ ជាកម្មកររោងចក្រ?

សនៈ បាទ!ជាកម្មកររោងចក្រក្រឡឹងដែក ។

វណ្ណៈ កន្លែងហ្នឹងគេហៅ"ដ៧"?

សនៈ បាទ!"ដ៧"ជិតរោងចក្រអគ្គិសនីទី២ផ្លូវចាក់អង្រែក្រោម ។

វណ្ណៈ បាទ ។

សនៈ តែកាលគេកើតសម័យចលនារួបរួមជាតិអាហ្នឹងខ្ញុំកំពង់តែរៀន តែមកដល់សព្វថ្ងៃហ្នឹងវាបាក់បែងឃ្លាតពីស្រុកឆ្ងាយមកដល់នេះ ។

វណ្ណៈ ចឹងកាលពូបែកចេញពីផ្ទះនៅឆ្នាំ៧៥ហ្នឹងពូអាយុប៉ុន្មានហើយ?

សនៈ កាលហ្នឹងអាយុ១៥ ។

វណ្ណៈ ចឹងកាលហ្នឹងអង្គការរើសចេញពីកងកុមារមក?

សនៈ អង្គការរើសចេញពីកងកុមារមក មកដាក់នៅភ្នំពេញនេះ កាលមុននៅប្រូតកាត់ដាក់ស្ពៃជាមួយហ្នឹងគេ កាលហ្នឹងរើដីធ្វើព្រែក គេថាព្រែកត្នោត កាលហ្នឹងដាំស្ពៃឲ្យអង្គភាពគេឲ្យបងៗ គេហូប ត្រូវការប្រលែប្រឡុកអីយកឲ្យគេ ។

វណ្ណៈ កាលឆ្នាំ៧៥ខែប៉ុន្មានមកដល់ហ្នឹង?

សនៈ មិនដឹងជាឆ្នាំ៧៥ខែប៉ុន្មានទេ ខ្ញុំដឹងថាខែប្រាំង ខែយើងនេះឯង បើមិនខែ១២ ខែ១ហ្នឹងឯងតែដឹងថាប្រូតកាត់រួចហើយ ខ្ញុំកាត់ស្មានទៅប្រហែលជាខែ២ ។

វណ្ណៈ ចឹងប្រហែលជាក្រោយហ្នឹងទៀតទេ ព្រោះខ្មែរក្រហមចូលថ្ងៃទី១៧មេសាឆ្នាំ៧៥ មានន័យថាចូលនៅថ្ងៃទី១៧ ខែ៤ហើយយកទីក្រុងភ្នំពេញបាននៅឆ្នាំ១៩៧៥ចឹងនៅពេលហ្នឹងគេមិនទាន់រើសកងកុមារមកទេ ចឹងរើសមកឆ្នាំ៧៥ដែរ តែប្រហែលជាខែ១១-១២ដឹង?

សនៈ កាលរើសចូលភ្នំពេញយើងកំពង់ប្រូតនេះ ។

វណ្ណៈ ចឹងប្រហែលជាខែ១១?

សនៈ បាទ! ព្រោះខ្ញុំជិះឡានខ្ញុំឃើញឪពុកខ្ញុំ ខ្ញុំចូលទៅផ្ទះទៅឪពុកខ្ញុំប្រាប់ថាបងឯងទៅច្រូតបាត់ហើយ ។

វណ្ណៈ ចឹងបងប្អូនពូបង្កើតចូលចលនាមុនពូ?

សនៈ បាទ ។

វណ្ណៈ កាលហ្នឹងចូលប៉ុន្មាននាក់?

សនៈ ចូលពីរនាក់ ។

វណ្ណៈ ចឹងបាត់ខ្លួនទាំងពីរ?

សនៈ បាទ ។

វណ្ណៈ កាលហ្នឹងគាត់ចូលតាំងពីឆ្នាំណាមក?

សនៈ ខ្ញុំមិនបានដឹងគាត់ដងកាលនោះ គាត់ចូលកាលសម័យរដ្ឋប្រហាហ្នឹង ។

វណ្ណៈ ចឹងមានតែឆ្នាំ៧០ ?

សនៈ បាទ! តាមស្មានប្រហែលជាឆ្នាំ៧១ - ៧២ ។

វណ្ណៈ បងមានឈ្មោះអីខ្លះ?

សនៈ បងឈ្មោះ សេន ។

វណ្ណៈ ចឹងមួយទៀតឈ្មោះអីដែរ?

សនៈ ឈ្មោះ សុិន សាំ បាត់សម័យរដ្ឋប្រហា ហើយសុិន សេនហ្នឹងទើបតែស្លាប់ប្រហែលជាបួន ប្រាំខែមុន មួយទៀត សុិន សស្លាប់ដែរ មួយទៀតស្រីស្លាប់សម័យហ្នឹងដែរ ។

វណ្ណៈ ចឹងកាលពូបែកពីម៉ែឪហ្នឹងអាយុប្រហែលជាប៉ុន្មាន?

សនៈ ខ្ញុំចូលប្រហែលជាអាយុ១៧ទៅ១៨ហើយ ធ្វើជាកម្មកររោងចក្រ ។

វណ្ណៈ ចឹងកម្មករហ្នឹងពេលពូចូលទៅដល់ដំបូងឃើញមានមនុស្សច្រើនទេ?

សនៈ អត់ឃើញមនុស្សទេ ក្នុងភ្នំពេញនោះ ឃើញតែមានមនុស្សកន្លែងកម្មករទេ ខាងក្រៅមិនមានឃើញមនុស្សទេ ។

វណ្ណៈ តែកន្លែងកម្មករពូមានគ្នាប៉ុន្មាននាក់?

សនៈ ក្នុងក្រុមមានគ្នាប្រហែលជា២០នាក់ នៅខាងស្ទៃដែកណាស់ចាក់គ្រឿងបូមទឹក មានម៉ាសុីនបោក ។

វណ្ណៈ ចឹងពូមានចេះក្រឡឹងទេ?

សនៈ ខ្ញុំនៅខាងធ្វើពុម្ពឲ្យគេ ដូចជាកង់យោងចេះទៅខ្ញុំធ្វើរួចចាក់ឲ្យគេ រួចមានគេយកទៅក្រឡឹង ។

វណ្ណៈ ចឹងមានអ្នកក្រឡឹងផ្សេងទៀតចឹងមនុស្សមនុស្សរាប់រយនាក់ហើយ?

សនៈ បាទ! តែមាននុស្សច្រើនដែរ តាមផ្នែកៗវា តែមានតែបរវេនហ្នឹងទេ តាមផ្ទះថ្មអីអត់មានមនុស្សនៅទេ ស្ងាត់ជ្រាប ។

វណ្ណៈ ចឹងផ្ទះថ្មក្នុងភ្នំពេញគ្មានមនុស្សនៅ?

សនៈ បាទ! មានតែតាមកន្លែងដូចជាទីស្នាក់ការចឹងទើបមាន មានកន្លែងកុមារកំព្រាកន្លែងបាយទឹកទើបមានមួយផ្នែកចឹងទៅ កាលដែលខ្ញុំនៅភ្នំពេញហ្នឹងឃើញចឹងឯង ។

វណ្ណៈ ចឹងពូឃើញសភាពយ៉ាងម៉េចទៅស្ងាត់ឬមួយយ៉ាងម៉េច?

សនៈ ស្ងាត់ពុំមានផ្សារលក់ដូរទេ តែភ្លើងមានដោយកន្លែងមិនភ្លឺទាំងអស់ដែរ ។

វណ្ណៈ ចឹងភ្លើងអគ្គីសនីមានទេ?

សនៈ មានតែតាមរោងចក្រអីចឹង គេប្រើប្រាស់នោះណាស់ ក្រៅពីនោះមិនមានទេ ។

វណ្ណៈ ចឹងនៅតាមថ្នល់មានទេ?

សនៈ អត់ មានមួយៗ មានតាមបង្គោលភ្លើងវាដាច់ឆ្ងាយចឹងទើបមានមួយ តែបើនិយាយតាមរោងចក្រភ្លឺគ្រប់កន្លែង ចាប់ពីស្ពានជ្រោយចង្វារហូតចាក់អង្រែក្រោមខ្ញុំដឹងតែម៉ាចំណុចផ្លូវហ្នឹងហើយ ។

វណ្ណៈ ចឹងជិនាន់បីឆ្នាំពូបាននៅក្នុងភ្នំពេញរហូតដល់រត់យួនចូលមកតែម្តង?

សនៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងពូមានសិទ្ធដើរពីណាមកណាខ្លះដែរ?

សនៈ ខ្ញុំមិនមានសិទ្ធដើរទេ មានតែម្តុំរោងចក្រហ្នឹងហើយ ។

វណ្ណៈ ចឹងហេតុអីបានដឹងថាពីស្ពានជ្រោយចង្វារអីទៅ?

សនៈ កាលស្ពានជ្រោយចង្វារនេះ ដូចថាគេប្រើទៅរោងចក្រខ្ញុំនេះ កាលហ្នឹងបើដើរ ដើរជាក្រុមដើរជាអង្គភាព ។

វណ្ណៈ បាទ ។

សនៈ ដូចជាជិះឡានទៅធ្វើចំការអីណាអីណា ដូចជាចំការចេក ទៅធ្វើចំការខាងព្រែកឯងគេហៅព្រែកឯង ។

វណ្ណៈ ចឹងព្រែកឯងទៅដែរ?

សនៈ	បាទ! កាលហ្នឹងបឹងដំពន់បឹងអីហ្នឹងបានទៅហ្នឹងឯង ដូចថាដូចយើងដើរទៅចំការចេះមិនបាន ទេ កាលហ្នឹងជិះឡាន ។

វណ្ណៈ	ចឹងនៅកន្លែងក្រឡឹង«ដ៧» ហ្នឹងគេធ្វើអីខ្លះ?

សនៈ	ទី១ គឺគ្រឿងហូបទឹក ។

វណ្ណៈ	មានស្អីទៀត?

សនៈ	ទី២ គ្រឿងម៉ាស៊ីនបោកស្រូវ ទី៣ គ្រឿងម៉ាស៊ីនកិនស្រូវ ។

វណ្ណៈ	កាលហ្នឹងធ្វើបានយកទៅប្រើប្រាស់ហើយឬនៅឬមួយមិនទាន់ទេ?

សនៈ	ធ្វើបានសាកទាំងអស់ កាលហ្នឹងធ្វើរួចដាក់ឃ្លាំង គេថាអាមួយនេះយកទៅឲ្យស្រុកនេះអា នេះយកទៅឲ្យឃុំនោះ ធ្វើមិនមែនតិចទេ ធ្វើបាន៣០០ទៅ៤០០ម៉ាស៊ីននោះ សម័យហ្នឹង តែមិនដឹងជាធ្វើយកទៅណា ម៉ាស៊ីនកិនស្រូវដូចគ្នា ម៉ាស៊ីនបូមទឹកដូចគ្នា ម៉ាស៊ីនបូតស្រូវដូច គ្នា ឃើញតែលទ្ធផលនោះឃើញថាវាអាចលូតលាស់មែន ឃើញតែវាច្រើនហ្នឹងនិយាយ តែបរវេនពួកខ្ញុំធ្វើទេ មានរោងចក្រផ្សេងៗ ដល់យួនចូលមកមិនបានធ្វើ ។

វណ្ណៈ	ម៉េចបានយួនចូលមកបានជំនាន់ហ្នឹង?

សនៈ	កាលហ្នឹងខ្ញុំដឹងដែរ សេនាធិការធំបំផុតខាងទាហានតា វ៉ៃ ឈ្មោះ តា វ៉ៃ កាលនោះ ។

វណ្ណៈ	ឈ្មោះតា វ៉ៃ?

សនៈ	កាន់កងទ័ពនោះ គាត់ជាអ្នកប្រកាសថាយើងនៅភ្នំពេញមិនបានទេ គេចូលភ្នំពេញហើយ យួនចូលមកហើយ យួនដាំតែអុងណាណីទេ ចុះសង្គ្រាមធម្មតានយោបាយគេចេះតែ និយាយឲ្យក្រោមៗគេស្តាប់ទៅ បើគេមិននិយាយចុះវាអត់កំលាំងចូលទៅខាងគេ ម្ល៉ោះ ហើយគេនិយាយចេះទៅក៏ទៅតាមគេទៅ តែមិនបានឃើញជាក់ស្តែងទេ រហូតដល់យកខ្ញុំ ហ្នឹងទៅខាងបូព៌ាជិកឡានទៅឆ្លងទន្លេបាសាក់ខាងនោះស្ពានជ្រោយចង្វារខាងកើត តាមព្រៃ ក្តាម ដល់ទៅដល់ហ្នឹងគាត់ថាចាំម៉ោង៣ ហើយតាំងពីព្រឹករហូតដល់ម៉ោង៣ហើយមិនទាន់ បានហូបបាយទេ ហើយដល់នេះទៅយួនចូលពីខាងនេះឯង យួនចូលតាមបូព៌ាហ្នឹងចូលដល់ ភ្នំពេញ ចូលមកដល់គេថាយកកាំភ្លើងមកឲ្យហើយ ហើយពួកខ្ញុំ៣០០នាក់អត់មានកាំភ្លើង ទាំងអស់ ហើយគេទៅក្រោយខាងនេះរត់រួចអស់ ខ្ញុំក៏ហែលទឹកទន្លេបាសាក់ ។

វណ្ណៈ	បាទ ។

សនៈ ហើយទឹកទន្លេបាសាក់នោះមនុស្សស្លាប់មិនតិចទេ ចុះជិះទូកយួនឃើញមានមនុស្សច្រើនបាញ់ រកកន្លែងមនុស្សច្រើនហ្នឹងហើយ ។

វណ្ណៈ ចឹងកាលហ្នឹងឆ្នាំ៧៩ ហើយដែលយួនចូលមក?

សនៈ បាទ!៧៩ហើយ ក្រោយមកខ្ញុំរសាត់អណ្តែតមកដល់ភូមិនេះ ដើររត់លួតតាមគេមក បើតាមឲ្យខ្ញុំស្មគ្រ័នោះខ្ញុំមិនចង់បាកបែកឪពុកម្តាយទេ និយាយទៅរឿងខ្វាចណាមួយគ្មានអ្នកទីពឹងទៅចេះតែតាមគេទៅ ស្រុកភូមិវាឆ្ងាយ មកតាមគេទៅចេះតែអណ្តែតៗមកដល់ខ្ញុំបាន គ្រួសារក៏ខ្ញុំឈប់ខ្លួនឯងបណ្តោយ គិតឃើញទៅវាមិនអន់ចិត្តអីទេ ស្លាប់មនុស្សមិនបាន ឃើញមុខអីទេ ឃើញខ្មិលសម្រាកទៅធ្វើស្រែចំការចិញ្ចឹមប្រពន្ធកូនវិញចុះ បើគិតពីរកស៊ីវិញតាំងពីមុនមកដល់សព្វថ្ងៃនេះបានមិនតិចទេ ។

វណ្ណៈ បាទ ។

សនៈ តែនិយាយទៅដោយសារតែសន្តមប្រែប្រួល មិនបានអន់ចិត្តអីទេ តែសព្វថ្ងៃបើគេធ្វើជាប់គេមានបានចឹងទៅ តែខ្ញុំគេកើតមេធំៗសព្វថ្ងៃហ្នឹងគេមិនស្គាល់យើងផង ឃើញមុខគេមិនហៅយើងផង ដល់ពេលគេផ្តាច់ខ្លួនអីទៅ ខ្ញុំក៏មិនប្រកាន់ តែកាលសម័យស្និតស្នាញពឹងខ្ញុំហើយពីនេះទៅដើមអំពិលទឹកក៏បាញ់គ្នាកើតដែរ គេបោកគ្រាប់ក៏ហួសយើងបោកទៅគេវិញក៏ហួសទៅដែរ កាលនោះបាញ់គ្នាមិនធម្មតាទេ ។

វណ្ណៈ ចឹងកាលហ្នឹងមានស្លាប់រស់ច្រើន?

សនៈ បាទ!ឈាមប្រឡាក់ យើងឈរបាញ់ចេះ ខ្លះឈាមមកប្រឡាក់ខ្លួនឯងក៏មាន ។

វណ្ណៈ ចឹងខ្ញុំចង់ដឹងពីរឿងធ្វើក្រឡឹងនៅភ្នំពេញកាលបីឆ្នាំហ្នឹង?

សនៈ បាទ ។

វណ្ណៈ ចឹងពូថាមានម៉ាស៊ីនកិនស្រូវ ម៉ាស៊ីនបូមទឹករាបរយគ្រឿងមែនទេ?

សនៈ បាទ ។

វណ្ណៈ ចឹងថាដាក់នៅឃ្លាំងចោល ចឹងដល់ក្រោយមកពូមានដឹងរបស់ទាំងអស់ហ្នឹងមានគេបញ្ជូនទៅតាមជនបទអីទេ ឬមិនទាន់បានបញ្ជូនទេរបស់ទាំងអស់ហ្នឹង?

សនៈ តែត្រង់ថាបញ្ជូនហ្នឹងខ្ញុំមិនបានដឹងទេ គេគ្រាន់តែប្រាប់ថារបស់ហ្នឹងគេយកទៅតាមសហករណ៍ប៉ុណ្ណឹងទេ តែការបញ្ចេញពីឃ្លាំងនោះខ្ញុំមិនបានឃើញទេ ខ្ញុំបានតែធ្វើ ។

វណ្ណៈ ចឹងមានឃើញបាត់ពីកន្លែងហ្នឹងទេ?

សនៈ ព្រោះនៅកន្លែងឃុំឃាំងមានគេអ្នកកាន់ផ្សេង ដូចថាមានមួយផ្នែកទៀតទៅ មានមេគេសម្រាប់ទុកម៉ាស៊ីនការពារ ចេញឬចូលតាមតែគេទៅ ។

វណ្ណៈ ចឹងប្រធានពួនៅរោងចក្រ«ដ៧» ប្រធានពួឈ្មោះអីទៅ?

សនៈ ឈ្មោះ សនដូចខ្ញុំចឹងឯង ។

វណ្ណៈ ស្រីឬប្រុស?

សនៈ ប្រុស ។

វណ្ណៈ ចឹងមានអនុប្រធានអីទៀតទេ?

សនៈ អនុប្រធានមិនបានស្គាល់ទេ ។

វណ្ណៈ ចឹងសនហ្នឹងគាត់នៅរហូតដល់រត់៧៩ដែរឬយ៉ាងម៉េច?

សនៈ កាលហ្នឹងក្រោយមកគេថាស៊ីរូងផ្ទៃក្នុងអីគេទេ ឃើញយោធាគេមកច្រើនមិនដឹងជាគេចាប់គាត់ឬមួយយ៉ាងណា

ពួកខ្ញុំគ្រាន់តែឃើញចឹងមិនហ៊ានមើលគេក៏គេចខ្លួនចូលកន្លែងបាត់ទៅ ។

វណ្ណៈ ចឹងក្រោយមកឃើញបាត់ខ្លួនទេ?

សនៈ បាទ! បាត់គាត់ចូលមកម្នាក់ទៀតឈ្មោះអីណាទេ ។

វណ្ណៈ ចឹងសនហ្នឹងបាត់ខ្លួននៅឆ្នាំណា?

សនៈ នៅមុនយួនចូលបន្តិច ។

វណ្ណៈ ចឹងប្រហែលជា៧៨ហ្នឹង?

សនៈ បាទ ។

វណ្ណៈ ចូលក្រោយក្រោយឈ្មោះអី?

សនៈ មិនដឹងជាឈ្មោះអី តែខ្វាក់ភ្នែកម្ខាងទៀត ។

វណ្ណៈ មកពីខាងខាងណា?

សនៈ ម្នាក់ហ្នឹងមិនដឹងជាមកពីខាងនិរតីឬខាងបូព៌ាទេ ។

វណ្ណៈ ចឹងពូមិនបានដឹងច្បាស់ទេ?

សនៈ បាទ ។

វណ្ណៈ ចឹងជាកម្មករដូចជាពូចឹង មានពីណាធ្វើខុសអីត្រូវគេយកទោសពៃរ៍អីមានទេ?

សនៈ មានតែគេស្ដីបន្ទោស ។

វណ្ណៈ ចឹងអត់មានបាត់ខ្លួនទៅណាទេ?

សនៈ	បាទ!អត់ទេ ។

វណ្ណៈ	ចឹងកន្លែងពូសុទ្ធតែប្រុសៗមិនមានស្រីៗធ្វើការជាមួយទេ?

សនៈ	អត់មានទេ សុទ្ធតែប្រុសទាំងអស់ ។

វណ្ណៈ	ចឹងដែលឃើញមានស្រីៗទេ?

សនៈ	មានស្រីៗខាងដាំបាយ បើនិយាយទៅរឿងបាយសម័យនោះបើនិយាយរឿងជីវភាពវិញ ហូបតែនំប៉ុងមួយកំណាត់ទេក្នុងមួយពេល មានព្រឹកមួយពេល ល្ងាចមួយពេលប៉ុណ្ណេះឯង ។

វណ្ណៈ	ចឹងនៅឆ្នាំណាបានបាយ?

សនៈ	ផុតពីនោះមកគេថា តា ប៉ុល ពតមកមើលហើយ ខ្ញុំកាលហ្នឹងកំពង់តែវៃធ្យូងថ្ម កំពង់តែវៃ ធ្យូងថ្មគាត់បើកឡាន មានកង់បួនមុខកាប៊ុបៗនឹង គាត់មកនិយាយថា កូនឯងវៃឲ្យល្អអាហ្នឹង ថ្ងៃណាស់ ដល់នេះកាលហ្នឹងខ្ញុំកូនក្មេង ខ្ញុំនិយាយថា វៃមិនវៃអីខ្ញុំធ្វើខ្ញុំវៃហើយ ស្អាតមិន ស្អាតចាំតែមកមើលទៅ បើខ្ញុំធ្វើកខ្វក់ខ្ញុំឈប់ធ្វើហើយ ខ្ញុំកាលហ្នឹងមិនដឹងថាគាត់ជាតា ប៉ុល ពតទេ ។

វណ្ណៈ	បាទ ។

សនៈ	ហើយនិរសាគាត់មានគ្រាប់ពេញហ្នឹង គាត់បេះដេញដោលសួរខ្ញុំ ហើយគាត់ថាកូននេះបេះមាត់កយ៉ាងនេះ ហើយគាត់សួរថា សព្វថ្ងៃកូនឯងបានអីហូប ខ្ញុំថាដល់ម៉ោងគេចែកនំប៉ុងមួយកំណាត់ប្រវែងនេះ ខ្ញុំធ្វើដៃចឹង គាត់ថាហូបនំប៉ុងចឹងមានកំលាំង ខ្ញុំថាមានមិនមានបេះតែធ្វើទៅការងារគេឲ្យធ្វើហើយ តែគាត់មិនខឹងទេ គាត់មកសួរដូចមកសម្ភាសន៍បេះឯង ខ្ញុំនិយាយម៉ាស្អាតឲ្យគាត់ដឹង ហើយបើមិនជឿខ្ញុំទៅកន្លែងដាំបាយទៅ គ្មានបាយហូបទេមានតែនំប៉ុង ចុងភៅមានដែលពិបាកដាំបាយមានតែស្លមួយមុខប៉ុណ្ណឹងឯង គាត់ថាមែនក៏អីកូនខ្ញុំមិនដែលនិយាយកុហក់កូនក្មេងខ្ញុំថាបេះ ដល់ហើយចាប់ពីស្អែកទៅពុកឲ្យហូបមួយថ្ងៃបីពេលហើយគាត់ថាចឹង ដល់ស្អែកមែនវៃដួងហូបបីពេលដូចគាត់ថាចឹង ។

វណ្ណៈ	ចឹងកាលហ្នឹងហូបនំប៉ុងបានរយៈពេលមួយឆ្នាំទេ?

សនៈ	គិតទៅមិនបានមួយឆ្នាំទេ ជាងកន្លះឆ្នាំ ទៅព្រៃទៅណាក៏ដាក់នំប៉ុងជាប់ ។

វណ្ណៈ	ចឹងក្រោយមកបានបាយរហូត?

សនៈ	បាទ!ក្រោមមកហូបបាយ ។

វណ្ណៈ	ចឹងហូបបាយដល់ឆ្នាំ៧៩?

សនៈ	បាទ ។

វណ្ណៈ	កាលហ្នឹងបានហូបផ្អែតទេ?

សនៈ	ហូបផ្អែតមានបន្ថែមទៀត តែខ្ញុំនិយាយកន្លែងធ្វើការខ្ញុំទេ តែតាមជនបទខ្ញុំមិនបានដឹងទេ មានជួបការលំបាកចាប់មនុស្សទៅវៃ ទៅទាត់ធាក់នោះខ្ញុំមិនបានឃើញទេ បើកន្លែងខ្ញុំ ខ្ញុំនិយាយមិនបន្លាច់បន្លួចម្នាង១ទេ ខ្ញុំឃើញខ្លួនឯងផ្ទាល់ ។

វណ្ណៈ	បាទ ។

សនៈ	ខ្ញុំនិយាយតាមខ្លួនឯងឃើញ ខ្ញុំមិនចេះនិយាយឲ្យហួសទេ បើខ្ញុំនិយាយ១រឿងត្រូវដែលឃើញហ្នឹងភ្នែក និយាយមិនឲ្យខុសទេ និយាយឲ្យលើសចេះចុះខ្ញុំអត់ទេ ។

វណ្ណៈ	បាទ ។

សនៈ	និយាយតាមជាក់ស្តែងខ្លួនឯង តែបើនិយាយកាលឆ្នាំ៧០ខ្ញុំមិនបានដឹងច្បាស់ទេ ចាប់ពី៧៥ មកហ្នឹង រហូតដល់ខ្លួនប៉ុននេះរហូតមានប្រពន្ធកូនចៅខ្ញុំដឹង ធ្លាប់តស៊ូមកក្នុងព្រៃក្នុងផ្សៃ ការ ងារដែលខ្ញុំធ្វើតាំងពីសម័យនោះមក តាមរោងចក្ររោងអី ។

វណ្ណៈ	ចឹងសម័យហ្នឹងមានដឹងថា មានអ្នកធំណាខ្លះទៅលេងរោងចក្រអី?

សនៈ	កាលហ្នឹងខ្ញុំបានឃើញគេទៅទស្សនៈកិច្ច មានដែលឃើញច្រើនតាំងពីបារាំង មានកូរេខាងខ្មែរយើងមានខាងនារីស្រែអំបិល មានពួកកូរេទៅមើលកន្លែងធ្វើនោះ មានពុកឈ្មោះថាជប៉ុនដែលតែខ្ញុំមិនបានឃើញ ។

វណ្ណៈ	ចឹងមានជនបរទេសច្រើនដែរ?

សនៈ	មានមិនសូវច្រើនទេ ដែលខ្ញុំឃើញមានបារាំង កូរេ កាលនោះកូរេមានជំនួយឡានដែលហ្នឹង មានឡានដឹងជញ្ជូន ។

វណ្ណៈ	កាលហ្នឹងកូរេខាងណា កូរេខាងជើងឬខាងត្បូង?

សនៈ	មិនដឹងជាកូរេខាងណា ។

វណ្ណៈ	ចឹងមិនដែលឃើញចិនទេ?

សនៈ	មានចិនដែរ ចិនកាលហ្នឹងចិនម៉ៅសេទុងនិងគាត់ត្រូវគ្នាណាស់ កាលសម័យហ្នឹង ។

វណ្ណៈ	ពូមិនដែលមកលេងវាំងទេ កាលសម័យហ្នឹង?

សនៈ	ខ្ញុំដើរមកវិមានឯករាជ្យ ដើរទៅស្តាត តែឥឡូវស្តាតមិនដឹងណាទេ វាប្លែក ។

វណ្ណៈ	ចឹងពូមានដែលមកប្រជុំនៅស្តាតទេ?

សនៈ	មក ។

វណ្ណៈ	មកប៉ុន្មានដង?

សនៈ	មកពីរដង ។

វណ្ណៈ	ចឹងមានពីណាចូលរួមខ្លះមានប៉ុល ពតដែរ?

សនៈ	បាទ!គាត់មក ខ្ញុំស្គាល់តែគាត់មួយមិនដឹងជាពីណាទៀតទេ ។

វណ្ណៈ	ចឹងតា នួន ជា តា អៀង សារី តា ខៀវ សំផនមានស្គាល់គាត់ទេ?

សនៈ	កាលហ្នឹងមិនទាន់ស្គាល់ទេ តែក្រោយមកស្គាល់កាលសង្គ្រាម សម័យយួនចូលនេះស្គាល់គាត់ ។

វណ្ណៈ	ចឹងកាលជំនាន់ខ្មែរក្រហម ស្គាល់តែប៉ុល ពត?

សនៈ	បាទ!គាត់អ្នកនិយាយនៅលើស្ដាតហ្នឹងឯង ។

វណ្ណៈ	គាត់និយាយថាយ៉ាងម៉េចខ្លះ?

សនៈ	ដូចអ្នករោងចក្រចេះ គាត់និយាយថាយើងមុនធ្វើអីមួយយើងត្រូវប្រយ័ត្ន កុំឲ្យមានគ្រោះថ្នាក់ ដូច្នេះយើងចាប់អីមួយយើងចាប់ឲ្យជាប់ កុំចាប់ចុងដៃចុងជើង ខ្លាចវាធ្លាក់ត្រូវជើងត្រូវដៃ យើងត្រូវប្រយ័ត្នមើលឆ្វេងមើលស្ដាំមុននិងដើរចូល ដោតភ្លើងប្រយ័ត្នមានមាត់រន្ធបែកប្រយ័ត្នវាឆក់ គាត់ប្រាប់វាគ្រោះថ្នាក់ខ្លួនយើង គាត់និយាយច្រើនដែរ ដល់ចប់ទៅទៅមើលសិល្បៈអីគេទៅ នៅស្ដាតហ្នឹង ។

វណ្ណៈ	ចឹងនៅជំនាន់ខ្មែរក្រហមបីឆ្នាំហ្នឹង មានដឹងថាសម្ដេចគេឃុំខ្លួនព្រះអង្គនៅក្នុងវាំងអីមានដឹងទេកាលហ្នឹង?

សនៈ	ដឹងតែឃុំ តែខ្ញុំមិនបានឃើញទេ ខ្ញុំមិនដឹងថាគេដាក់នៅទន្លេមុខបួនឬដាក់នៅក្នុងវាំង កាលហ្នឹងគ្នាឯងដែលជុំគ្នាហ្នឹង គេថាសម្ដេចឪមិនទាន់ចេញពីប្រទេសឯណា ដល់ក្រោយមកទៀត បានបាត់ទៀត បាត់ដំណឹងឈឹងតែតាមការពិតសម្ដេចឪនៅក្នុងវាំងហ្នឹងឯង ដល់ក្រោយ មកទៀតលែងព្វនិយាយអីកាលហ្នឹងពួកខ្ញុំជិះឡានមកតាមទន្លេមុខបួន បាត់អ្នកបំរើគាត់ទាំង អស់មិនដឹងជាទៅឯណាកាលឆ្នាំ៧៦-៧៧នេះបាត់ដំណឹងគាត់ជ្រាបតែម្ដង ។

វណ្ណៈ	ចឹងកាលឆ្នាំ៧៥មានដឹងថាគាត់នៅណា?

សនៈ	ដឹងថាគាត់នៅវាំងហ្នឹងហើយ តែគេមិនឲ្យគាត់ទៅណាមកណា ។

វណ្ណៈ	ចឹងនៅក្នុងសម័យខ្មែរក្រហមហ្នឹងដែលពូមានដឹងថាទួលស្លែងមានគុកអីពូមានបានដឹងទេ?

សនៈ	មិនបានដឹងទេ ខ្ញុំដឹងថាសម័យខ្មែរក្រហម មិនថាជ្រុលខ្លួនឬខុសខ្លួនទេ ខ្ញុំសម័យដែលយួនចូលនេះទេ បានកាន់កាំភ្លើងបណ្តោយ តែសម័យកាប់សម្លាប់នោះខ្ញុំនៅជាកម្មករ ។

វណ្ណៈ	បាទ ។

សនៈ	មិញទ្រាសាននេះថា ចាំខ្មែរក្រហមហើយ ខ្ញុំចាំមែន កាលពីមុនមកខ្ញុំមិនដែលស្គាល់គាត់ទេ ទើបមកជួបគាត់នៅទីនេះទេ គាត់ខាងកាន់ទូរលេខ ពួកខ្ញុំហ្នឹងខាងវៃបណ្តោយ ក្បាលរឹងណាស់ខ្ញុំ ។

វណ្ណៈ	បាទ ។

សនៈ	ហើយទ្រាសានគាត់កាន់ទូរលេខ ចុចទៅខាងទន្លេសាបចឹងទៅចុចទៅខាងប៉ុស្តិ៍ចឹងទៅ ។

វណ្ណៈ	ចឹងខ្ញុំចង់សួរថា កាលឆ្នាំ៧៩យួនចូលមកហេតុអីបានជាពូមិនរត់ទៅស្រុកកំណើត?

សនៈ	ព្រោះខ្ញុំជឿរឿងចឹងឯង យើងគិតថាគេឃោសនាក៏ថាបាន ព្រោះខាងផ្នែកនយោបាយគេថាដូចនេះមិនហ៊ានរត់ទៅផ្ទះវិញ គេថាយួនបរបថក្រោះអីកិន មើលទៅខ្លួនឯងឃើញសង្គ្រាមទល់មុខជងនោះ មិនហ៊ានសម្រេចចិត្តទៅផ្ទះ ដូចនេះចេះតែមកតាមគេទៅ ទោះបីយប់ប្រលប់ ចេះតែតស៊ូទៅឲ្យតែបានដុត ។

វណ្ណៈ	ចឹងកាលនៅជិតនាប់បីឆ្នាំពូមានដែលសុំគេមកលេងផ្ទះទេ?

សនៈ	សុំគេបានម្តង កាលនោះខ្ញុំមិនទាន់បានមកធ្វើការរោងចក្រទេ តែដល់ចូលរោងចក្រហើយសុំគេមិនបានទេ ។

វណ្ណៈ	កាលហ្នឹងអង្គការថាយ៉ាងម៉េច?

សនៈ	អង្គការថាវល់ ដូចជាគ្រឿងបូមទឹកចេះធ្វើមួយឆ្នាំៗមិនដែលសម្រាកទេ ដូចយើងនេះដែរក្រោកឡើងស្ងួងៗ កាលនោះដូចគ្នាចឹង មួយឆ្នាំគ្មានពេលសម្រាកទេ ធ្វើជាប់ ។

វណ្ណៈ	ចឹងមានម៉ាស៊ីនបូមទឹកច្រើន?

សនៈ	បាទ ។

វណ្ណៈ	ចឹងមើលតាមដាក់ស្តែងទៅ នៅតាមជនបទឃើញតែជីកប្រឡាយ មានម៉ាស៊ីនខ្លះដែរ តែម៉ាស៊ីននោះគេកែច្នៃដុតធ្យូង មួយសសហករណ៍អីមានមួយ?

សនៈ	ចឹងបានជាខ្ញុំឆ្ងល់អារឿងហ្នឹងឯង ។

វណ្ណៈ	កាលហ្នឹងគេយកកំលាំងមនុស្សធ្វើទាំងអស់ហ្នឹង?

សនៈ	បាទ ។

វណ្ណៈ	គេយកមនុស្សបាចទឹកដាក់ស្រែ?

សនៈ ខ្ញុំឃើញដានរហាត់ទឹកអីហ្នឹង ខ្ញុំថាទេ យ៉ាងម៉េចចឹង ។

វណ្ណៈ ចឹងកាលហ្នឹងពូធ្វើគ្មានពេលសម្រាកសោះ?

សនៈ បាទ!ខ្ញុំធ្វើមិនបានសម្រាក កាលហ្នឹងពួកខ្ញុំបើកឡានមកដល់ឃើញអ្នកស្រុកធាក់អាររហាត់នោះ បែកញើសរហាមខ្ញុំថាឆាប់ហើយ កាលនោះមានម៉ាស៊ីនរបស់ប្រទេសអាឡឺម៉ង់ជំនួយ ។

វណ្ណៈ ចឹងកាលហ្នឹងមានម៉ាស៊ីនអាឡឺម៉ង់ជំនួយទេ?

សនៈ បាទ!សុទ្ធតែរបស់អាឡឺម៉ង់ជំនួយ ។

វណ្ណៈ ចឹងកាលហ្នឹងសម្ភារនៅភ្នំពេញច្រើនណាស់?

សនៈ មានច្រើនណាស់ មីងខ្ញុំថា ឯងមិននៅភ្នំពេញចង់ខ្សែព័ទ្ធទៅ កន្លែងបរវេននោះមានប៉ុណ្ណាឯងព័ទ្ធទៅគ្មានពីណាហ៊ានចូលទេ មានពីណាហ៊ាននៅព្រោះខ្លាចនោះ តែបងប្អូនខ្ញុំមាន កាលហ្នឹងគេចូលទៅយកបានខ្លះដែរ ។

វណ្ណៈ ចឹងពូមានដែលទៅលេងស្រុកកំណើតទេ?

សនៈ ខ្ញុំបានទៅបីបួនដងហើយ ខ្ញុំនាំប្រពន្ធកូនខ្ញុំទៅ តែទៅគេមានជាងខ្ញុំ ចេះតែរកស៊ីតត់ទៅខ្ញុំអេនខ្មាស់គេដង សុខចិត្តពិបាកនេះតែឯងទៅ ។

វណ្ណៈ ចឹងកាលពូរត់ចេញពីទីក្រុងមក កាលហ្នឹងពូជិះអីមក?

សនៈ នៅពេលរត់ចេញពីក្រុងហ្នឹងខ្ញុំជិះឡានមក ។

វណ្ណៈ ចឹងជិះឡានមកដល់ណា?

សនៈ កាលហ្នឹងជិះឡានមកដល់ព្រែកក្តាមអីហ្នឹង ។

វណ្ណៈ ចឹងចេញពីព្រែកក្តាមដើរថ្មើរជើងវិញ?

សនៈ ដើរដោយជើងវិញហើយ ហែលពីទន្លេបាសាក់មកខាងកើតហ្នឹង ដល់ព្រែក្តាមខ្ញុំជិះសាឡាងឆ្លងទៅកើតទៀត ។

វណ្ណៈ ចឹងដើររហូត?

សនៈ ដើររហូតមកដល់ព្រំដែននេះ គ្មានបានជិះអីទេ ។

វណ្ណៈ ចឹងរហូតប៉ុន្មានខែបានមកដល់ព្រំដែន?

សនៈ កាលហ្នឹងយូរគ្រាន់ដែរ រៀបរាប់មកតាំងពីពោធិសាត់មកដល់បាត់ដំបងដំណាក់ៗមក មកដល់មង្គលបូរី មកដល់ម៉ាឡៃបណ្តោយ ម៉ាឡៃក៏ខ្ញុំនៅ ។

វណ្ណៈ ចឹងនៅពេលរត់មកតាមផ្លូវមានឃើញមនុស្សស្លាប់ទេ?

សនៈ អត់ឃើញមានស្លាប់ទេ ។

វណ្ណៈ ចឹងមានឃើញរណ្ដៅសាកសពថ្មីៗអីទេ?

សនៈ មិនបានឃើញទេ ព្រោះខ្ញុំដើរតែយប់ ។

វណ្ណៈ ចឹងហេតុអីមិនដើរនៅពេលថ្ងៃ?

សនៈ ខ្លាចឃ្លូនថ្ងៃសម្រាក ។

វណ្ណៈ ចឹងកាលហ្នឹងមិនប្រឡំធ្វើប្រជាជនមកផ្ទះវិញ?

សនៈ ខ្ញុំខ្លាចគេអ្នកស្រុកហ្នឹងទៀត ចុះសម័យនោះខ្ញុំគ្រាន់តែសុំទូកយាយតាម្នាក់នោះជិះ គាត់ថាខ្ញុំអាពតៗចង់កាប់ខ្ញុំ តាមកាលពិតទៅខ្ញុំមិនដឹងថាអាពតនោះយ៉ាងណាទេ នេះជាគំនិតខ្ញុំចុះវាមិនបានដឹងសោះ ខ្ញុំមិនដឹងថាខាងក្រោយវាលំបាកប៉ុណ្ណា បានជាទឹងខ្លាំងយ៉ាងនេះ គាត់ថាអាពតៗកុំឲ្យវាជិះ ។

វណ្ណៈ ហើយពូថាយ៉ាងម៉េចទៅ?

សនៈ ខ្ញុំថាអាពតយ៉ាងណាចេះខ្ញុំឆ្លល់នោះ ព្រោះខ្ញុំមិនបានដឹងសោះ ខ្ញុំក៏ទាញគល់ឫស្សីបានហែលទឹកទៅ កាលហ្នឹងខ្ញុំឃើញកាំភ្លើងធំបាញ់ទូកដាច់ពីរបីកំណាត់ឈាមពេញទន្លេបាសាក់ហ្នឹង អាខ្លះគ្នាហែលមិនរួចនិយាយរួមទៅច្រើនតែមនុស្សស្រី បងៗនារីកាលសម័យនោះលិចទឹកងាប់ច្រើនណាស់ មានអ្នកបើកយន្តហោះក៏មានស្លាប់នៅហ្នឹងដែរ បងដែលជាអ្នកបើកយន្តហោះបានជួយនារីនោះម្នាក់ យកមកដល់ក៏សន្ធប់ហ្នឹង ច្រាំងខាងលិចច្រាំងជ្រោយចង្វារហ្នឹង រួចហើយគាត់សុំលារត់មកព្រោះខ្លាច នៅពេលឃ្លូនចូលដល់ភ្នំពេញប្រហែលជាម៉ោង៩ទៅម៉ោង១០ បើខុស ខុសតិចនៅពេលឃ្លូនចូលភ្នំពេញព្រោះខ្ញុំរត់យប់ចូលបាញ់ខ្លូសេតឆេះ ឃ្លាំងសាំង មើលទៅឃើញកស្តតាំងវាស្ដែងពេកខ្ញុំសម្រេចចិត្តថាមិនហ៊ានរត់ទៅភូមិ ។

វណ្ណៈ បាទ ។

សនៈ ភូមិខ្ញុំអាផ្លូវទៅភ្នំពេញហ្នឹងតាមផ្លូវជាតិលេខ៤ ។

វណ្ណៈ បាទ ។

សនៈ វាជិតហ្នឹងពោធិចិនតុងហ្នឹង ដូចនេះខ្ញុំមិនហ៊ានទៅទេ កាលហ្នឹងខ្លូសេតាញ់មកភ្លើងឆេះប៉ុននេះ ចឹងខ្ញុំមិនហ៊ានទៅផ្លូវទៅតាមហ្នឹងឯង ។

វណ្ណៈ ចឹងកាលហ្នឹងពូរត់មកដល់ម៉ាឡៃនៅឆ្នាំណា?

សនៈ កាលហ្នឹងឆ្នាំ៨០មកដល់ម៉ាឡៃ ព្រោះនៅឆ្នាំ៨៤ឃ្លូនមកដល់ព្រំដែនឈើប ។

វណ្ណៈ ចឹងកាលមកដល់ម៉ាឡៃនៅឆ្នាំ៨០ ហ្នឹងពូមកនៅផ្ទុំណា?

សនៈ កាលហ្នឹងខ្ញុំនៅអូរស្រឡៅ ខ្វាផាប់ សំពៅលូន កាលហ្នឹង នៅគីឡូ១២ ជាលានដ្ឋានខ្ញុំហើយ កាលយួនបុកខ្ទាំងនៅគីឡូ១២ ។

វណ្ណៈ បាទ ។

សនៈ ជីកត្រង់សេចេះយួននៅចេះ ។

វណ្ណៈ ចឹងកាលហ្នឹងសុទ្ធតែព្រៃឬយ៉ាងម៉េច?

សនៈ កាលនោះព្រៃដើរមិនចង់រួចទេ មិនដូចសព្វថ្ងៃទេ មានតែផ្លូវថៅកែយ៉ម៉កហ៊ុនទេ បើខុសផ្លូវដើរមិនរួចទេ ។

វណ្ណៈ មានដើមឈើធំៗប៉ុណ្ណាទៅ?

សនៈ ដើមឈើប៉ុនៗពាង មានដើមឈើទាល ។

វណ្ណៈ ចឹងគេថាឲ្យចូលដល់ក្នុងមើលថ្ងៃមិនឃើញមែនឬយ៉ាងម៉េច?

សនៈ មើលមិនឃើញទេ បើយប់ចេះដីមានពន្លឺ មិនមែនដូចសព្វថ្ងៃទេ ។

វណ្ណៈ ភ្លឺដោយសារអី?

សនៈ ភ្លឺដោយសារជាតិស្លឹកឈើ ។

វណ្ណៈ ចឹងខ្វះមានជាតិបារត?

សនៈ ហ្នឹងហើយមានជាតិបារតហ្នឹងឯង បើជ្រុះអីរបស់អីមើលទៅឃើញខ្មៅ ដូចជាគ្រាប់កាំភ្លើងធ្លាក់ទៅមើលឃើញ ។

វណ្ណៈ ចឹងពន្លឺហ្នឹងភ្លឺច្បាស់ទេ?

សនៈ ភ្លឺម៉ាល្មមៗជិតៗហ្នឹង ដូចថាទ្រនាប់ជើងយើងដោះចេះមើលទៅឃើញទ្រនាប់ជើងយើងចឹងទៅ ។

វណ្ណៈ កាលហ្នឹងគ្រុនចាញ់យ៉ាងម៉េចដែរ?

សនៈ កាលហ្នឹងគ្រុនចាញ់មិនមានថ្នាំលេបទេ ។

វណ្ណៈ ចឹងមានជំងឺគ្រុនចាញ់ស្លាប់ច្រើនទេ?

សនៈ ស្លាប់មិនតិចទេ កាលហ្នឹង ខ្ញុំក៏ជួបដែរ ជួនឈរបត់ជើងតូចចេះដួលផ្កាប់មុខផុសមិនបានដឹងខ្លួនថាដួលទេ ស្រាប់តែដឹងខ្លួននៅពេទ្យហើយ ។

វណ្ណៈ ចឹងកាលហ្នឹងពូមានចិត្តព្រួយបារម្ភណ៍ថាផាប់មិនបានទៅស្រុកវិញទេ?

សនៈ	ភ័យថាខ្លួនមិនបានរស់ទេ ព្រោះផាប់នៅជិតៗខ្ញុំចេះហើយ ដល់ក្រោយមានគេជំនួយតើបានមានសាច់មានឈាមដល់សព្វថ្ងៃនេះ បើគ្មានជំនួយផាប់បាត់ហើយ ។

វណ្ណៈ	ចឹងកាលនៅម៉ាឡៃជាយោធាខ្មែរក្រហមហ្នឹង កាលហ្នឹងពីណាជាអ្នកកាន់កាប់?

សនៈ	កាលហ្នឹងតា ភាព ។

វណ្ណៈ	ចឹងប្រធានកងពលមុខតា ភាពនោះ?

សនៈ	មុនតា ភាពខ្ញុំមិនបានដឹងទេ ។

វណ្ណៈ	ចឹងតា កន តា ហុងនោះ?

សនៈ	តា កន តា ហុងគាត់មកនៅច័ន្ទក្រហមនេះវិញទេ តា ហុងខ្ញុំឮឈ្មោះដែរ តែនិយាយឲ្យច្បាស់តាភាពហ្នឹងឯង ។

វណ្ណៈ	ចឹងពូមកនៅម៉ាឡៃហ្នឹងបានប៉ុន្មានឆ្នាំដែរបានពូមកនៅទីនេះ?

សនៈ	នៅម៉ាឡៃហ្នឹងនៅយូរគ្រាន់ប្រហែលជាបីឆ្នាំនោះ ។

វណ្ណៈ	ចឹងឆ្នាំណាបានពូមកនៅទីនេះ?

សនៈ	កាលហ្នឹងឆ្នាំ៨៤យួនបុកប៉ាប់បាញ់ខ្ញុំ ខ្ញុំរត់ចូលដីថៃ គេថាជំរំស្រះកែវ ។

វណ្ណៈ	ចូលដីថៃយ៉ាងម៉េចទៀតទៅ?

សនៈ	ចូលដីថៃស្រះកែវធ្វើជំរំនៅនោះ ថៃវាក្តុងបាញ់ទៀតហ្នឹង នៅស្រះកែវហើយត្រឡប់មកវិញ ។

វណ្ណៈ	ចឹងហេតុអីបានជាពូមិនទៅក្រៅប្រទេស?

សនៈ	ទៅក្រៅវាមានពាក់ព័ន្ធច្រើនណាស់ ។

វណ្ណៈ	ពាក់ពន្ធ័រឿងអីទៅ?

សនៈ	ពាក់ព័ន្ធរឿងអាបារាំងក៏ស្រឡាញ់ អាមេរិកក៏ស្រឡាញ់ដូចនេះវាមិនឲ្យទៅព្រោះបារាំងវាខំចិញ្ចឹមនោះ ខំឲ្យបាយឲ្យអីហូបហើយយើងមកយកគេយ៉ាងម៉េច បារាំងគេថាខំចិញ្ចឹម វាដេកពាំងថ្នល់មិនឲ្យទៅក៏ចុះមកវិញ ដល់ចឹងខ្ញុំក៏ត្រឡប់មកខ្មែរវិញ ។

វណ្ណៈ	ត្រឡប់មកខ្មែរវិញនៅឆ្នាំណា?

សនៈ	ត្រឡប់មកខ្មែរវិញប្រហែលជាឆ្នាំ៧/៨ ។

វណ្ណៈ	ចឹងនៅឆ្នាំ៨៧ហ្នឹងពូនៅម៉ាឡៃឬមួយពូនៅទីណា?

សនៈ	ឆ្នាំ៨៧មកនៅម៉ាឡៃវិញ តែនៅភូមិដូង ។

វណ្ណៈ	ចឹងយ៉ាងម៉េចទៀតមកនៅម៉ាឡៃហ្នឹង?

សនៈ នៅម៉ាឡៃហ្នឹងបានមួយរយៈប្រហែលជា៥ខែ ខ្ញុំក៏មកខាងច័ន្ទក្រហមព្រៃមាន់ហ្នឹង ។

វណ្ណៈ ចឹងខ្ញុំចង់ដឹងកាលនៅម៉ាឡៃ ចឹងកាលនៅម៉ាឡៃយោធាខ្មែរក្រហមមិនមានប្រាក់ខែទេ?

សនៈ មិនមានទេ ។

វណ្ណៈ ចឹងកាលឡើងវៃជាមួយយួនមានដែលចាប់បានយួនទេ?

សនៈ មានចាប់បាន ។

វណ្ណៈ ពេលចាប់បានធ្វើយ៉ាងម៉េចទៅ?

សនៈ ចាប់បានយកទៅដូរអំបិល ។

វណ្ណៈ យកទៅដូរណាវិញ?

សនៈ យកទៅដូរគេហៅថាភ្នំដី ភូមិដូងហ្នឹងហើយ ។

វណ្ណៈ កាលហ្នឹងមានចាប់បានយួនច្រើនទេ?

សនៈ មានចាប់បានច្រើនដែរ គេថាជនឈើយសឹកចាប់បានយួនមួយដូរអំបិលបានពីរឡានកាលសម័យនោះ ហើយកាលហ្នឹងមិនជឿថាយួនមកឈ្លានពានខ្មែរទេ មកបាញ់ខ្មែរទេកុំនិយាយកុហក់ចង់បានដីថៃចេះចុះ ។

វណ្ណៈ ចឹងកាលហ្នឹងយកយួនទៅដូរជាមួយពីណា?

សនៈ កាលហ្នឹងយកទៅដូរជាមួយថៃ ។

វណ្ណៈ យ៉ាងម៉េចបានជាថៃយកទាហានយួនទៅវិញ?

សនៈ យកទៅអាមេរិកដឹងខ្ញុំមិនបានដឹងដែរ បើងាប់ក៏ដូរបាន ។

វណ្ណៈ ចឹងដោះដូរជាមួយថៃ?

សនៈ បាទ ។

វណ្ណៈ ពូបានដឹងច្បាស់ទេ?

សនៈ បើគេថាដូរៗ បើចាប់បានដាច់ដៃដាច់ជើងចេះព្យាបាលឲ្យជា ហើយសួរថាចង់ត្រឡប់ទៅណាឲ្យទៅៗ បើកំពង់តែបាញ់គ្នាចេះ បើចំអ្នកចិត្តឆាវមិនដឹងទេ ។

វណ្ណៈ ចឹងទាហានយួននិងទាហានខ្មែរខាងក្នុងមានចាប់បានទាហានខ្មែរក្រហមយកទៅទេ?

សនៈ ដូចជាមិនដែលបានឃើញផង ម្នាក់ៗដូចជាមិនឲ្យចាប់បានសោះ ។

វណ្ណៈ ចឹងកាលហ្នឹងទាហានយួនស្លាប់ច្រើនទេ?

សនៈ កាលច្បាំងគ្នាហ្នឹងទាហានយួនងាប់ច្រើនណាស់ មិនតិចរយពាន់នាក់ទេ ។

វណ្ណៈ ចឹងរាប់ពាន់នាក់?

សនៈ បាទ ។

វណ្ណៈ ចឹងទាហានខ្មែរយើងមកជាមួយយណមានស្លាប់ទេ?

សនៈ មានស្លាប់ដូចគ្នា ។

វណ្ណៈ ចឹងទាហានខ្មែរក្រហមមានស្លាប់ច្រើនដែរ?

សនៈ ទាហានខ្មែរក្រហមជួនណាបាញ់មួយប្រាំវទៅងាប់បីបួននាក់ដែរ ច្រើនតែរបួស តែខាងយួនងាប់ច្រើនមែនខ្ញុំឃើញ ។

វណ្ណៈ ចឹងខាងកំលាំងខ្មែរក្រហមកាំភ្លើងគ្រាប់អីបានមកពីខាងណា?

សនៈ កាលហ្នឹងពួថាយកមកពីចិន តែចូលតាមរយៈដីថៃហ្នឹង ។

វណ្ណៈ ចឹងមានបានដឹងថា ខាងថៃវាមានផលប្រយោជន៍អីខ្លះពីខ្មែរក្រហម បានជាមានពេលខ្លះជួយផ្តល់កន្លែងឲ្យខ្មែរក្រហម?

សនៈ តាមខ្ញុំគិតមើលបើអត់មានប្រយោជន៍គេមិនឲ្យនៅទេ ប្រយោជន៍សំខាន់តែបើនិយាយទៅវាវែងឆ្ងាយ ។

វណ្ណៈ និយាយទៅមានអី?

សនៈ វាច្រើនពេក ។

វណ្ណៈ ប្រយោជន៍សំខាន់យ៉ាងម៉េចទៅ?

សនៈ ប្រយោជន៍សំខាន់ដូចជាការពារឲ្យវាផងទៅ ។

វណ្ណៈ ចឹងខ្មែរក្រហមជារនាងឲ្យវាដែរ?

សនៈ បាទ!ម្យ៉ាងទៀតវាចំនិញដី យើងឈ្មោះគ្នាវាបង្កិតបង្គោលទី១ ដែលវាឆៀតឱកាសនោះ ។

វណ្ណៈ បាទ ។

សនៈ ចឹងហើយ ដូចនេះវាសុខចិត្តជួយគាំទ្រហើយ វាពង្រីកភូមិឲ្យអ្នកស្រុកវាទៅ ហើយសំខាន់មួយទៀត តាមខ្ញុំដឹងប្រហែលជាបានជំនិញខ្លះហើយបានជាវាជួយ ដូចជាឆ្លងកាត់ក្នុងមួយដើងថ្ងៃប៉ុន្មាន វាបានលុយទៅវាខ្លះ ដល់ក្រោយមកទៀតខ្ញុំឈប់ធ្វើទាហានមកធ្វើស្រែចំការខ្ញុំលែងដឹងពួហើយ ។

វណ្ណៈ ចឹងកាលនៅម៉ាឡៃពូមានបានដឹងថា សម្តេចចុះមកផ្តល់សាគាំងអីយ៉ាងម៉េចនោះពូមានបានដឹងទេ?

សនៈ កាលនោះខ្ញុំជាអ្នកទទួល កាលហ្នឹងទទួលគាត់ឈរកាន់កាំភ្លើងចឹង ។

វណ្ណៈ ចឹងកាលហ្នឹងឈរការពារ?

សនៈ បាទ!ឈរការពារសម្តេច ។

វណ្ណៈ កាលហ្នឹងឆ្នាំណា?

សនៈ កាលហ្នឹងខ្ញុំភ្លេចអារឿងឆ្នាំហ្នឹងទៅ ។

វណ្ណៈ ចឹងពូជាអ្នកការពារ?

សនៈ បាទ ។

វណ្ណៈ ចឹងមានអ្នកកាសែតច្រើនទេ?

សនៈ មានច្រើន មានតាំងពីឥណ្ឌាមកដែរ ។

វណ្ណៈ ចឹងឆ្នាំណាពូមកនៅកន្លែងនេះ?

សនៈ ដូចខ្ញុំនិយាយចឹងឆ្នាំ៨៤យួនដេញរត់ទៅថៃ រួមត្រឡប់មកវិញចូលម៉ាឡៃដែរ តែចេញពីម៉ាឡៃមកទីនេះនៅឆ្នាំ៨៤ដដែល ។

វណ្ណៈ ចឹងកន្លែងដែលពូមកនៅទីនេះ គេហៅថាតំបន់អី?

សនៈ គេហៅថាតំបន់ច័ន្ទក្រហម ភ្នំឆត្រ ក្បាលលាវ ។

វណ្ណៈ តំបន់ច័ន្ទក្រហមនៅភូមិអី?

សនៈ គេថាក្បាលលាវ ។

វណ្ណៈ ចឹងឃុំអី?

សនៈ គ្មានឃុំអីទេ កាលនោះស្រុកថៃនោះ ។

វណ្ណៈ ចឹងច័ន្ទក្រហមក្បាលលាវស្រុកថៃ?

សនៈ បាទ ។

វណ្ណៈ ចឹងពេលចេញមកវ៉ៃធ្វើយ៉ាងម៉េចទៅ?

សនៈ ពេលចេញមកស្នាក់នៅតាមព្រៃ តាមត្រពាំងថ្មល់ចេះទៅ អូរប្រាសាទ ។

វណ្ណៈ កាលហ្នឹងនៅស្រុកអីគេ?

សនៈ ស្រុកថ្មពួក ភ្នំព្រះគ្រប់តែកន្លែង ។

វណ្ណៈ ចឹងច័ន្ទក្រហមភ្នំព្រះហ្នឹងមានខ្មែរក្រហមផងប៉ុរាជផង?

សនៈ កាលហ្នឹងនៅច្របូលច្របល់គ្នា ។

វណ្ណៈ ចឹងខ្មែរក្រហមនិងប៉ុរាជជួបគ្នាមានវ៉ៃគ្នាទេ?

សនៈ កាលហ្នឹងគេហៅថាភាគីចម្រុះ កាលឆ្នាំ៨៦-៨៧ឈប់វ៉ៃគ្នាហើយត្រូវគ្នាវិញ កាលហ្នឹងរួមគ្នាវ៉ៃយួនតែមួយ តែមានឈ្លោះគ្នាម្តងម្កាលដែរ ។

វណ្ណៈ ចឹងនៅខាងទឹកដីហ្នឹងពីណាកាន់កាប់?

សនៈ មានតា ថាន់ តា វួយ ។

វណ្ណៈ គាត់ជាប្រធានកងពល?

សនៈ បាទ!ប្រធានកងពល តា ឌុល សារឿន តា ហុងយើងនេះ ។

វណ្ណៈ ចឹងតា ហុងមកដល់ហ្នឹងដែរ?

សនៈ បាទ! តា ហុង តា វួយ ។

វណ្ណៈ ចឹងកាលជំនាន់វ៉ៃគ្នាហ្នឹងនៅម្តុំនេះជាព្រៃឬមួយវាលចឹង?

សនៈ នៅម្តុំនេះវាលអាចធ្វើស្រែបានតិចៗចេះឯង ដូចសព្វថ្ងៃ បើព្រៃខ្ទាំងចាប់ពីនោះកន្ទុយដូន ព្រៃខ្ទាំងហើយខាងនោះ តែសព្វថ្ងៃវាលអស់ហើយ ។

វណ្ណៈ ចឹងនៅវាលចឹងពេលបាញ់ឃើញគ្នា?

សនៈ ឃើញរត់ចឹង ដួនកាលលូនទៅគិតៗទៅខ្លាចដែរ បាញ់គ្នាក៏ឈ្លៀមឈប់បាញ់ក៏ឈ្លៀម ។

វណ្ណៈ កាលហ្នឹងមានកើតភូមិច្រើនហើយនៅ?

សនៈ អត់ទេ មានផ្ទះតូចៗមួយៗឆេះអស់ទៅខ្លះក៏ងាប់គោក្របី ។

វណ្ណៈ ចឹងពូរៀបការនៅឆ្នាំ៨៧?

សនៈ បាទ ។

វណ្ណៈ ចឹងរៀបការហើយឈប់ធ្វើទ័ព?

សនៈ បាទ!ប្រកបការងារកសិករ ។

វណ្ណៈ ចឹងគេមិនរករឿងទេ បើយើងឈប់ធ្វើចឹង?

សនៈ កាលហ្នឹងគេមកតាមដែរ តែខ្ញុំនិយាយរឿងជាក់ស្តែងប្រាប់គេអស់ គេរករឿងដែរ ដល់យូរៗទៅគេដកតែកាំភ្លើងអីទៅ ឲ្យសម្ភារយោធាឲ្យគេវិញអស់ទៅ ។

វណ្ណៈ ចឹងកាលឆ្នាំ៩៣មានបានបោះឆ្នោតទេ?

សនៈ បានបោះ ។

វណ្ណៈ ចឹងមានអ៊ុនតាក់មកទេ?

សនៈ មានអ៊ុនតាក់មក ។

វណ្ណៈ ចឹងខ្ញុំចង់សួរពូទាក់ទងរឿងតុលាការវិញម្តង ពូក៏ធ្លាប់ឆ្លងកាត់ភាពជូចត់ខ្លះដែរ ទោះបីពូមិនបានដឹងថា នៅខាងក្រោយមានការហូបចុកលំបាក តែពូនៅខាងមុខមានអាហារហូបគ្រប់គ្រាន់ចឹង?

សនៈ	បាទ ។

វណ្ណៈ	ចឹងពូគិតថាមានតុលាការខ្មែរក្រហមហ្នឹង ជាការត្រឹមត្រូវឬមួយមិនត្រឹមត្រូវទេ?

សនៈ	អារឿងកាត់ទោសហ្នឹងខ្ញុំមិនហ៊ាននេះដែរ និយាយឲ្យចំទៅខ្ញុំមើលមិនឃើញ ហើយចំណុចដែលខ្ញុំឃើញហ្នឹង ឃើញតែរឿងផ្ទាល់ខ្លួន ខ្លួនឯងទេ ។

វណ្ណៈ	បាទ ។

សនៈ	មិនដែលជួបកាលលំបាក តែបើមើលឃើញថា ម៉ាស៊ីនធំធ្វើម៉េចមិនឃើញយកមកប្រើ ឃើញតែដាន់រហាត់ទឹកវិញ បាបទឹកដាក់ស្រែអាហ្នឹងខ្ញុំឃើញមែន ។

វណ្ណៈ	ចឹងខ្ញុំសួរពូថាចេះ ពូគិតថាមានតុលាការកាត់ទោសចឹងឬមួយមិនមានតុលាការល្អជាង?

សនៈ	ខ្ញុំថាទៅខ្លាចលោនេះ ។

វណ្ណៈ	មិនអីទេ ជាទស្សនៈរបស់ពូ? បើពូនិយាយយ៉ាងម៉េចមិនមានពាក់ព័ន្ធនិងនយោបាយដែរ តែគ្រាន់តែចង់ដឹងមតិប្រជាជន ព្រោះយើងរាល់ថ្ងៃនេះមានតុលាការជាតិផងនិងអន្តរជាតិផង តែចិត្តពូវិញគិតថា មិនបាច់កាត់ទោសទេ គាត់ចាស់ហើយ ហួសហើយ តែបើពូគិតថាគាត់ចាស់តែគាត់បានធ្វើខុសត្រូវតែកាត់ទោសឬក៏យ៉ាងម៉េច ខ្ញុំគ្រាន់តែចង់ដឹងមតិរបស់ពូទេ?

សនៈ	ចិត្តខ្ញុំរកនិយាយមិនកើត ខ្ញុំមិនដឹងទេ ។

វណ្ណៈ	មិនអីទេពូ ។

សនៈ	ខ្ញុំសព្វថ្ងៃគិតតែរឿងជីវភាពខ្លួនឯង ខ្ញុំមិនហ៊ានឆ្លើយទេ ។

វណ្ណៈ	បាទ ។

សនៈ	ខ្ញុំមិនហ៊ានឆ្លើយទេ ។

វណ្ណៈ	ចឹងពូមានស្គាល់ឌុចពីមុនមកទេ?

សនៈ	ខ្ញុំតាឌុចមិនដែលស្គាល់មុខគាត់យ៉ាងណាទេ ទើបដឹងថាឌុចជាប្រធានគុកទួលស្លែង ពីមុនមកមិនបានដឹងទេ ។

វណ្ណៈ	ចឹងគេប្តឹងផ្ទះឌុច ពូគិតថាជារឿងគំនុំឬជារឿងដែលគេប្តឹងចង់បានទ្រព្យសម្បត្តិគាត់?

សនៈ	រឿងប្តឹងឌុចនោះខ្ញុំមិនបានដឹងទេ ។

វណ្ណៈ	ចឹងរាល់ថ្ងៃពូធ្វើស្រែ?

សនៈ	បាទ ។

វណ្ណៈ	ចឹងពូមានបើករបបទាហានទេ?

សនៈ អត់ទេ ។

វណ្ណៈ ចឹងពូឈប់យូរហើយ?

សនៈ ឈប់យូរហើយ រាល់ថ្ងៃខំប្រឹងខ្លួនឯង ។

វណ្ណៈ ចឹងពូមានបំណងចង់ទៅស្រុកកំណើតវិញឬមួយអត់ទេ?

សនៈ ចង់ដែរ តែវាខ្មាស់គេ បើទៅលេងទៅ បើស្រុកកំណើតនិយាយឲ្យចំទៅគេកើតរោងចក្រជុំវិញផ្ទះអស់ហើយ ។

វណ្ណៈ បាទ ។

សនៈ យើងទៅនោះយើងមិនមានដីស្រែឲ្យកូនដង ។

វណ្ណៈ ចឹងខ្ញុំអរគុណពូច្រើនហើយ ។

សនៈ បាទ ។

**ចប់**